Khmer



# វិធីសាស្ត្រប្រឆាំងគ្រឿងញៀននៅកាប្រាម៉ាតា – រយៈពេល ១២ ខែដំបូង

ប័ណ្ណព័ត៌មាន ■ ខែឧសភា ឆ្នាំ 2002

នៅខែមីនា ឆ្នាំ 2001 រដ្ឋាភិបាលបានប្រកាសនូវផែនការទូលំទូលាយមួយដែលចំណាយទឹកប្រាក់ 18,8 លានដុល្លារ ដើម្បីដោះស្រាយបញ្ហាគ្រឿងញៀននិងឧក្រិដ្ឋកម្ម នៅក្នុងកាប្រាម៉ាតា។

វិធីសាស្ត្រប្រឆាំងគ្រឿងញៀននៅកាប្រាម៉ាតា (Cabramatta Anti-Drug Strategy) មានរួមទាំង:

- ចំនួនប៉ូលិសនិងធនធានបន្ថែម ដើម្បីបិទផ្ទះជួញដូរគ្រឿងញៀន និងបំបាត់អ្នកជួញដូរគ្រឿងញៀន និងអ្នកប្រើគ្រឿងញៀននៅតាមដងផ្លូវ;
- ការព្យាបាលជាចាំបាច់ខាងមិនបានសំរាប់អ្នកប្រើគ្រឿងញៀន និងការពង្រីកសេវាកម្មព្យាបាលនិងជួយធ្វើឲ្យអ្នកប្រើគ្រឿងញៀនមានសភាពប្រសើរឡើងវិញ;
- កម្មវិធីក្រុមឃ្លាំមើលក្រុង (City Watch) ដើម្បីធ្វើឲ្យប៉ូលិសនិងសហគមន៍ក្នុងតំបន់ រួមដៃគ្នាក្នុងការបង្កើតដំណោះស្រាយទៅនឹងឧក្រិដ្ឋកម្មក្នុងតំបន់; ហើយនិង
- ការពង្រីកកម្មវិធីបង្ការនិងធ្វើអន្តរាគមន៍មុនពេលទាំងឡាយ – ដូចជា Gateways (ផ្លូវចេញចូល) និងក្រុមធ្វើការតាមដងផ្លូវកាប្រាម៉ាតា (Cabramatta Street Team) ។

ការបញ្ចេញការផ្តួចផ្តើមទាំងពួងបានចាប់ផ្តើមឡើងនៅថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2001 ។ មកទល់នឹងថ្ងៃនេះ គេបានទទួលលទ្ធផលគួរឲ្យលើកទឹកចិត្តខ្លះ យ៉ាងណាមិញ កិច្ចការត្រូវធ្វើ នៅមានច្រើននៅឡើយនៅក្នុងកាប្រាម៉ាតា។

ប័ណ្ណព័ត៌មាននេះ ពន្យល់ដោយសង្ខេបនូវចំណុចសំខាន់ៗទាំងឡាយនៃការរីកចំរើននៅក្នុងការផ្តួចផ្តើមទាំងឡាយ ដើម្បីឲ្យមានវិធីសាស្ត្រប្រឆាំងគ្រឿងញៀន។

រដ្ឋាភិបាលនឹងបន្តពិនិត្យឲ្យដិតដល់ លើការរីកចំរើនក្នុងកាប្រាម៉ាតា។

## អំណាចនិងធនធានថ្មីសំរាប់ប៉ូលិស

វិធីសាស្ត្រប្រឆាំងគ្រឿងញៀននៅកាប្រាម៉ាតា បង្កើតឲ្យមានអំណាចថ្មីសំរាប់ប៉ូលិស និងធនធានបន្ថែមសំរាប់ការងារប៉ូលិសនៅក្នុងតំបន់។

ចាប់តាំងពីខែមករា ឆ្នាំ 2001 មក ផ្ទះជួញដូរគ្រឿងញៀនចំនួន 75 បានត្រូវបិទទ្វារនៅក្នុងកាប្រាម៉ាតា ហើយផ្ទះ 15 ក្នុងចំណោមផ្ទះទាំងនេះ បានត្រូវបិទទ្វារដោយសារការប្រើច្បាប់ទាំងពួងដែលដាក់ឲ្យប្រើនៅថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2001 ។

ចាប់តាំងពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2001:

- មនុស្ស 51 នាក់ ក្នុងកាប្រាម៉ាតា បានជាប់ចោទពីបទស្ថិតនៅក្នុង ចូលទៅក្នុង និងចាកចេញពីផ្ទះជួញដូរគ្រឿងញៀន;
- មនុស្ស 16 នាក់ក្នុងកាប្រាម៉ាតា បានជាប់ចោទពីបទរៀបចំ ឬ ចាត់ចែងផ្ទះជួញដូរគ្រឿងញៀន;
- មនុស្ស 209 នាក់ បានជាប់បទចោទនៅក្នុងតំបន់ប៉ូលិស Greater Hume ដោយមានបទចោទចំនួន 288 ទាក់ទងនឹងការផ្គត់ផ្គង់គ្រឿងញៀន; ហើយ
- បញ្ជា"បណ្តេញចេញពីទីកន្លែង"ចំនួន 3 214 បានធ្វើឡើងនៅក្នុងកាប្រាម៉ាតា។

**ធនធានប៉ូលិស បានបង្កើន:**

- ទីបញ្ជាការប្រចាំតំបន់មូលដ្ឋាន (Cabramatta Local Area Command) កាប្រាម៉ាតា ដែលតម្លើងទៅជាកំរិតទី 1 នៅក្នុងការទទួលស្គាល់ថា កាប្រាម៉ាតាគឺជាតំបន់ត្រូវការកិច្ចការប៉ូលិសយ៉ាងស្មុគស្មាញ ដែលគួរតែមានអាទិភាព;
- ស្ថានីយប៉ូលិសកាប្រាម៉ាតាថ្មីមួយ អស់ទឹកប្រាក់ 12,78 លានដុល្លារ ដែលកំណត់ចប់សព្វគ្រប់នៅត្រឹមពាក់កណ្តាលឆ្នាំ 2003;
- មកទល់នឹងពេលនេះ មានការបំពេញមុខដំណែងចំនួន 5 ក្នុងចំណោមមុខដំណែងបង្កើតថ្មីសំរាប់ភ្នាក់ងារស៊ើបអង្កេតគ្រឿងញៀនចំនួន 10 នាក់; ហើយនិង
- ក្រុមប៉ូលិសជិះកង់ (Bicycle Squad) ដែលឆ្លើយតបយ៉ាងលឿន ក៏បានបង្កើនពី 6 នាក់ ដល់ទៅ 12 នាក់ផងដែរ។

### អ្នកបកប្រែភាសា

ប៉ូលិសកាប្រាម៉ាតា អាចសុំឲ្យមានអ្នកបកប្រែភាសាទៅតាមតម្រូវការសំរាប់ភាសាសហគមន៍ទាំងឡាយ នៅក្នុងកាប្រាម៉ាតា។ ទីបញ្ជាការប្រចាំតំបន់មូលដ្ឋានកាប្រាម៉ាតា កំពុងប្រើសេវាកម្មបកប្រែភាសាប្រចាំការនិងតាមទូរស័ព្ទរបស់គណៈកម្មការទំនាក់ទំនងសហគមន៍ (Community Relations Commission) ហើយគណៈកម្មការនេះ បានជ្រើសរើសអ្នកបកប្រែភាសាវៀតណាមថែមទៀត សំរាប់ឲ្យធ្វើការនៅក្នុងកាប្រាម៉ាតា។

### ជំនាញការកាន់តែប្រសើរឡើងសំរាប់ប៉ូលិសដែលធ្វើការជាមួយសហគមន៍

ប៉ូលិស NSW បានរៀបចំឲ្យមានវគ្គសិក្សាវិញ្ញាបនបត្រឯកទេសមួយនៅ TAFE សំរាប់ភ្នាក់ងារប៉ូលិសនៃទីបញ្ជាការប្រចាំតំបន់មូលដ្ឋានកាប្រាម៉ាតា។ ប៉ូលិសកាប្រាម៉ាតាកំពុងទទួលការហ្វឹកហ្វឺនដើម្បីឲ្យចេះភាសាវៀតណាមជាគោលការណ៍ សំរាប់ការសន្ទនាយ៉ាងសាមញ្ញ និងការកត់ត្រានៅក្នុងរបាយការណ៍ឧក្រិដ្ឋកម្ម។ ភ្នាក់ងារទាំងនេះ ក៏នឹងយល់ដឹងអំពីវប្បធម៌និងប្រវត្តិសាស្ត្ររបស់វៀតណាមផងដែរ។ វគ្គសិក្សាខ្លីមួយ ក៏មានសំរាប់ភ្នាក់ងារប៉ូលិស នៅក្នុងតំបន់កាប្រាម៉ាតាផងដែរ។

នៅខែធ្នូ ឆ្នាំ 2001 ភ្នាក់ងារប៉ូលិសដំបូងចំនួន 13 នាក់ បានរៀនចប់វគ្គសិក្សាឯកទេសនៅ TAFE នេះ។ ភ្នាក់ងារប៉ូលិស 122 នាក់ថែមទៀត នៅក្នុងតំបន់កាប្រាម៉ាតា កំពុងចូលរួមបណ្តើរៗនៅក្នុងវគ្គសិក្សាខ្លីៗ អំពីជំនាញការនិងការយល់ដឹងអំពីវប្បធម៌។

Produced by the Community Drug Information Strategy, NSW Premier's Department.

ActNow NSW GOVERNMENT AND YOU
Taking a stand against drugs

## City Watch (ក្រុមឃ្លាំមើលក្រុង)

City Watch ធ្វើឲ្យប៉ូលិស អាជីវករ និងសហគមន៍ក្នុងតំបន់ ធ្វើការរួមគ្នាដើម្បីបង្កើតការឆ្លើយតបទៅនឹងឧក្រិដ្ឋកម្មក្នុងតំបន់។ ក្រុមនេះបាននិងកំពុងធ្វើប្រតិបត្តិការតាំងពីខែកក្កដាឆ្នាំមុន ហើយបានជួបប្រជុំគ្នាចំនួនប្រាំមួយលើកហើយ។

"ក្រុមទំនាក់ទំនង"សហគមន៍ចំនួនប្រាំពីរក្រុម បានបង្កើតឡើង គឺក្រុមឃ្លាំមើលតំបន់ជិតខាង, ក្រុមនាយកសាលារៀន, ក្រុមយុវជន, ក្រុមទំនាក់ទំនងបណ្ដាញព័ត៌មាននិងសាធារណៈ, ក្រុមខ្មែរមនុស្សចាស់, ក្រុមបញ្ហាយុវជននិងការងារប៉ូលិស ហើយនិងក្រុមពលរដ្ឋវ័យចាស់។ ក្រុមទាំងនេះផ្ដល់ឱវាទទៅឲ្យក្រុមប្រឹក្សាឃ្លាំមើលក្រុង (City Watch Council)។ ក្រុមថ្មីទាំងឡាយកំពុងតែបង្កើតបន្ថែម។

សេចក្ដីបារម្ភផ្សេងៗរបស់សហគមន៍កំពុងតែត្រូវបានលើកយកមកពិភាក្សា ហើយមានការចាត់សកម្មភាព ដើម្បីដោះស្រាយសេចក្ដីបារម្ភទាំងនេះ តាមរយៈ City Watch ឧទាហរណ៍: កង្វល់របស់សហគមន៍លើបញ្ហាពេស្យាកម្មនៅតាមដងផ្លូវជាដើម។

## ស្ថិតិឧក្រិដ្ឋកម្ម

យោងទៅតាមការិយាល័យស្ថិតិនិងការស្រាវជ្រាវឧក្រិដ្ឋកម្ម NSW (NSW Bureau of Crime Statistics and Research) គេឃើញមានការធ្លាក់ចុះនូវចំនួនឧក្រិដ្ឋកម្មទាំងពួងនៅខាងក្រោមនេះ ដែលកើតមាននៅក្នុងកាប្រាម៉ាតា ក្នុងអំឡុងពេលនៃខែមករា ឆ្នាំ 2000 ទៅទល់នឹងខែធ្នូ ឆ្នាំ 2001:

- ចោរកម្មរថយន្ត បានធ្លាក់ចុះចំនួន 37 ភាគរយ;
- ការលួចគ្រឿងពីរថយន្ត បានធ្លាក់ចុះចំនួន 24,8 ភាគរយ;
- អំពើលួចប្លន់ដោយមានអាវុធ ក្រៅអំពីកាំភ្លើង បានធ្លាក់ចុះចំនួន 7,1 ភាគរយ;
- អំពើលួចប្លន់ដោយគ្មានអាវុធ បានធ្លាក់ចុះចំនួន 4,9 ភាគរយ; ហើយ
- ជាទូទៅ បទល្មើសសព្វាវុធបានធ្លាក់ចុះចំនួន 19,2 ភាគរយ។

ការថយចុះលើការផ្គត់ផ្គង់ហេរ៉ូអ៊ីន ដែលគួបផ្សំនឹងការងាររបស់ប៉ូលិសក្នុងតំបន់ កំពុងមានផលប៉ះពាល់ជាខ្លាំង ទៅលើការប្រើហេរ៉ូអ៊ីននៅក្នុងកាប្រាម៉ាតា។

- បទល្មើសកម្មសិទ្ធិហេរ៉ូអ៊ីន បានធ្លាក់ចុះចំនួន 63,9 ភាគរយ;
- ចំនួនម្ជុលនិងសឺរ៉ាំងដែលចែកចាយពីសេវាកម្មអន្តរាគមន៍គ្រឿងញៀន (Drug Intervention Service) ទៅឲ្យអ្នកប្រើគ្រឿងញៀនក្នុងកាប្រាម៉ាតា បានធ្លាក់ចុះពី 40 239 នៅក្នុងខែមករា ឆ្នាំ 2001 មកនៅត្រឹម 9 991 នៅក្នុងខែមករា ឆ្នាំ 2002;
- ចំនួនហៅឡានពេទ្យទៅជួយអ្នកប្រើគ្រឿងញៀនហួសកំរិត បានធ្លាក់ចុះពី 385 នៅក្នុងឆមាសទីពីរនៃឆ្នាំ 2000 មកនៅត្រឹម 15 នៅក្នុងអំឡុងពេលដូចគ្នា កាលពីឆ្នាំមុន; ហើយ
- ចំនួនស្លាប់ពាក់ព័ន្ធនឹងគ្រឿងញៀន ក៏បានធ្លាក់ចុះពី 24 មកនៅត្រឹម 5 នៅក្នុងអំឡុងពេលដូចគ្នានេះដែរ។

## ការព្យាបាល (ការព្យាបាលនិងការធ្វើឲ្យប្រសើរឡើងវិញ)

ចាប់ពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2001 កម្មវិធីថ្មីពីរ គឺ**ការធានាឲ្យនៅក្រៅឃុំរបស់ប៉ូលិសលើបញ្ហាគ្រឿងញៀន (Police Drug Bail)** និង**ការបញ្ជូនមុនពេលដោយចៅក្រមឲ្យទៅទទួលការព្យាបាល (Magistrates Early Referral into Treatment / MERIT)** បានចាប់ផ្ដើមធ្វើឡើងនៅក្នុងកាប្រាម៉ាតា។ កម្មវិធីទាំងនេះ បញ្ជូនជនល្មើសដែលមានបញ្ហាគ្រឿងញៀន ឲ្យចូលទៅក្នុងសេវាកម្មព្យាបាលនិងធ្វើឲ្យល្អឡើងវិញ ដើម្បីបង្ការឧក្រិដ្ឋកម្មរាំរៃនឹងគ្រឿងញៀនតទៅទៀត ហើយកែលំអសុខភាពនិងសុខុមាលភាពរបស់បុគ្គលរៀងខ្លួន។

**គំរោងធានាឲ្យនៅក្រៅឃុំរបស់ប៉ូលិសលើបញ្ហាគ្រឿងញៀន** និង **ការបញ្ជូនមុនពេលដោយចៅក្រមឲ្យទៅទទួលការព្យាបាល (MERIT)** បាននិងកំពុងធ្វើប្រតិបត្តិការតាំងពីខែកក្កដា ឆ្នាំ 2001 ។

- នៅត្រឹមថ្ងៃទី 29 ខែមីនា ឆ្នាំ 2002 កម្មវិធី MERIT បានទទួលយកជនល្មើស 28 នាក់។ ជនល្មើស 13 នាក់ បានស្ថិតនៅក្នុងកម្មវិធីនេះ ហើយ 10 នាក់បានបញ្ចប់កម្មវិធីនេះ;
- នៅត្រឹមថ្ងៃទី 28 ខែកុម្ភៈ ឆ្នាំ 2002 ប៉ូលិសបានចេញបញ្ជាឲ្យជនល្មើស 21 នាក់ ចូលរួមនៅក្នុងការពិនិត្យវាយតម្លៃ និងការព្យាបាលគ្រឿងញៀន ជាលក្ខខណ្ឌនៃការធានាឲ្យនៅក្រៅឃុំ; ហើយ
- នៅត្រឹមថ្ងៃទី 20 ខែមីនា ឆ្នាំ 2002 ប៉ូលិសបានផ្ដល់ការធានាឲ្យនៅក្រៅឃុំសំរាប់ជនល្មើស 393 នាក់ ដោយដាក់លក្ខខណ្ឌមិនឲ្យវិលទៅកាន់កាប្រាម៉ាតាវិញ។

មន្ទីរពេទ្យ Liverpool បានរៀបចំមាន**ទីកន្លែងព្យាបាលគ្រឿងញៀន** ចំនួន 100 ថែមទៀត។ មកទល់នឹងពេលនេះ ចំនួនបន្ថែមនេះ បានបំពេញសេចក្ដីត្រូវការនៅក្នុងតំបន់។

**សេវាកម្មសុខភាពផ្លូវចិត្ត** បានពង្រីកឡើងសំរាប់អ្នកដែលមានបញ្ហាគ្រឿងញៀននិងសុខភាពផ្លូវចិត្ត។

**អាទិភាពទទួលព្រៃស្នាក់នៅសំរាប់ព្យាបាលធ្វើឲ្យប្រសើរឡើងវិញ** ចំនួន 4 កន្លែងទៀត បានបង្កើតឡើង។

**សេវាកម្មកណ្ដាលសំរាប់ពិនិត្យវាយតម្លៃ** បានបង្កើតឡើងដើម្បីសំរបសំរួលការពិនិត្យវាយតម្លៃ និងការបញ្ជូនអ្នកដែលត្រូវការសេវាកម្មព្យាបាលគ្រឿងញៀន។

រដ្ឋាភិបាលកំពុងធ្វើការជាមួយសាលាក្រុង Fairfield ដើម្បីរកមើលកន្លែងសមរម្យ សំរាប់ធ្វើជាមណ្ឌលព្យាបាលថ្មីមួយ។ មណ្ឌលព្យាបាលនេះនឹងផ្ដល់ថ្នាំឲ្យមនុស្សដល់ទៅ 300 នាក់។

### ទីលំនៅសំរាប់ពេលមានវិបត្តិ

ការផ្ដល់ឱកាសសំរាប់ឲ្យមានទីលំនៅមានស្ថិរភាព បានជួយបណ្ដាជនឲ្យរក្សាការសិក្សារបស់គេ, បន្តការធ្វើការងារ ហើយជួយអ្នកទាំងនេះឲ្យធ្វើដំណើរទៅកាន់ទិសដៅថ្មីមួយ។

អង្គការទីលំនៅសហគមន៍ Hume (Hume Community Housing) បានផ្ដល់ទីលំនៅបន្ថែមសំរាប់ពេលមានវិបត្តិ – ទីលំនៅរយៈពេលខ្លីចំនួន 40 និងទីលំនៅរយៈពេលយូរចំនួន 10 – នៅក្នុងកាប្រាម៉ាតា និងតំបន់នៅជុំវិញទាំងពួង។ ក្រុមយុវជន (Youth Team) នៃមជ្ឈមណ្ឌលសហគមន៍កាប្រាម៉ាតា ចាត់ចែងការបញ្ជូន និងបង្កើតដំណើរការសំរាប់ទីលំនៅទាំងនេះ ដោយទទួលការឧបត្ថម្ភប្រាក់ពីក្រសួងសេវាកម្មសហគមន៍ (Department of Community Services) ។ ក្រុមនេះក៏ចាត់ចែងវេនបុគ្គលិកប្រចាំការ សំរាប់"ទីលំនៅពេលមានវិបត្តិ"នៃអ្នកស្រវឹងផងដែរ។

ចាប់ពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2001 ដល់ខែមេសា ឆ្នាំ 2002:

- មនុស្ស 42 នាក់ បានទទួលទីលំនៅ;
- គ្រាសព្វថ្ងៃនេះ មនុស្ស 35 នាក់បានទទួលទីលំនៅ ដោយមានរួមទាំងប្រជាជនប្រាំពីរគ្រួសារ;

- ជន 14 នាក់ក្នុងចំណោមអ្នកទាំងនេះ បានសំរេចជោគជ័យក្នុងការធ្វើឲ្យការរស់នៅរបស់គេមានស្ថិរភាព ហើយរស់នៅក្នុងទីលំនៅទាំងនេះ អស់រយៈពេលជាច្រើនខែ។

### ការតភ្ជាប់អ្នកគ្មានទីលំនៅដែលប៉ះពាល់ដោយគ្រឿងញៀននិងសុរា ទៅកាន់សេវាកម្មនានា

ច្បាប់ជនស្រវឹង ឆ្នាំ 1979 (*Intoxicated Persons Act 1979*) អាចឲ្យប៉ូលិសឃុំខ្លួនជនស្រវឹងនិងគ្មានទីលំនៅញឹកញយ ដែលរកឃើញនៅតាមទីកន្លែងសាធារណៈ ហើយដែលអាចបង្កគ្រោះថ្នាក់ដល់ខ្លួនឯងឬអ្នកដទៃ។ បន្ទាប់មក ប៉ូលិសបញ្ជូនអ្នកទាំងនេះទៅកាន់គ្រួសាររបស់គេ ឬបញ្ជូនទៅកាន់កន្លែងព្យាបាល ទីលំនៅសមរម្យ និង សេវាកម្មឯទៀត។

ប៉ូលិស ក្រសួងសុខាភិបាល NSW និងក្រសួងសេវាកម្មសគមន៍ កំពុងបង្កើតពិធីការទាំងឡាយ អំពីរបៀបដែលប៉ូលិសបញ្ជូនជនស្រវឹងទៅកាន់សេវាកម្មសមស្របទាំងពួង។ ពិធីការក្នុងតំបន់កាប្រាម៉ាតាអំពីជនស្រវឹង (Cabramatta Intoxicated Persons Local Protocol) បានអនុវត្តឡើងនៅថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2001 ដើម្បីឲ្យកើតឡើងព្រមគ្នានឹងវិធីសាស្ត្រប្រឆាំងគ្រឿងញៀន។

មកទល់នឹងថ្ងៃទី 29 ខែមីនា ឆ្នាំ 2002:

- មនុស្ស 11 នាក់ បានត្រូវបញ្ជូននៅក្រោមពិធីការនេះ ទៅកាន់សេវាកម្មសុខាភិបាលទាំងពួង ដើម្បីធ្វើការពិនិត្យវាយតម្លៃជាបន្ទាន់អំពីលទ្ធភាពគ្រោះថ្នាក់ដល់សុខភាព (ចំនួន 3 នាក់ បានបដិសេធនូវការពិនិត្យវាយតម្លៃ);
- មនុស្ស 6 នាក់ បានទទួលការព្យាបាល ហើយ 2 នាក់ទៀតបានត្រូវបញ្ជូនទៅកាន់សេវាកម្មព្យាបាលឯទៀត;
- មនុស្ស 8 នាក់ បានទទួលទីលំនៅដែលផ្តល់ឲ្យដោយក្រុមធ្វើការតាមដងផ្លូវកាប្រាម៉ាតា នៅតាមផ្ទះដែលរៀបចំជាពិសេស សំរាប់ការប្រើប្រាស់នៅក្រោមពិធីការនោះ។

## អន្តរាគមន៍ និងវិធានការបង្ការ

ចាប់តាំងពីថ្ងៃទី 1 ខែកក្កដា ក្រុមដងផ្លូវនៃក្រសួងសេវាកម្មសហគមន៍ បានជួយបណ្តាជនវ័យក្មេង អ្នកគ្មានទីលំនៅ និងអ្នកទទួលផលប៉ះពាល់ដោយគ្រឿងញៀន ក្នុងការស្វែងរកទីលំនៅ និងទទួលជំនួយពីបណ្តាសេវាកម្មព្យាបាលគ្រឿងញៀននិងសុរា។ សេវាកម្មនេះ មានទីតាំងនៅឯស្នងការដ្ឋានប៉ូលិសកាប្រាម៉ាតា ហើយធ្វើប្រតិបត្តិការជារៀងរាល់ថ្ងៃ។

មកទល់នឹងថ្ងៃទី 17 ខែឧសភា ឆ្នាំ 2002 ក្រុមធ្វើការនៅតាមដងផ្លូវនេះ បាន:

- ធ្វើការទាក់ទងមនុស្ស 478 នាក់ នៅក្នុងពេល 933 លើក;
- ទទួលការទាក់ទងពីអ្នកដែលត្រូវការ ចំនួន 165 លើក;
- ទទួលការបញ្ជូនចំនួន 210 ពីប៉ូលិសក្នុងតំបន់; ហើយ
- បានបញ្ជូនមនុស្ស 296 នាក់ ទៅកាន់បណ្តាសេវាកម្មទីលំនៅហើយនិងគ្រឿងញៀននិងសុរា។

### ការជួយគ្រួសារក្នុងការដោះស្រាយបញ្ហាគ្រឿងញៀនខុសច្បាប់

គំរោងការងារ"ជំហានទៅមុខ"របស់ការថែទាំរួបរួម Burnside (Uniting Care Burnside's 'Moving Forward') ផ្តល់ជំនួយល្អិតល្អន់ទៅឲ្យគ្រួសារ ការពិគ្រោះឱវាទ និងការទទួលការព្យាបាលគ្រឿងញៀននិងសេវាកម្មឯទៀត ដែលអាចជាការចាំបាច់។

ចាប់តាំងពីពេលដែលកម្មវិធីនេះបានចាប់ផ្តើមនៅខែវិច្ឆិកា ឆ្នាំ 2001 ពលរដ្ឋ 17 គ្រួសារ ដោយមានរួមទាំងសមាជិកគ្រួសារ 22 នាក់ ដែលជាអ្នកប្រើគ្រឿងញៀន បានទទួលជំនួយ។

ក្រសួងសេវាកម្មសហគមន៍ ផ្តល់ប្រាក់សំរាប់គំរោងការងារនេះ។

### ការតភ្ជាប់គ្រួសារជាមួយនឹងសាលារៀននិងសហគមន៍នានា

**Gateway Program (កម្មវិធីផ្លូវចេញចូល)**

កម្មវិធី ***Gateways Program*** បានចាប់ផ្តើមកាលពីឆ្នាំមុន នៅក្នុងតំបន់កាប្រាម៉ាតា/Fairfield ។ កម្មវិធីនេះជួយសិស្សសាលាដែលប្រហែលជាជាប់ពាក់ព័ន្ធនឹងគ្រឿងញៀនឬមិនបញ្ចប់ Year 12 ។ មកទល់នឹងថ្ងៃទី 30 ខែមេសា ឆ្នាំ 2002:

- សិស្ស 124 នាក់ បានទទួលការគ្រប់គ្រងតាមករណីរៀងៗខ្លួន;
- សិស្ស 90 នាក់ បានបញ្ចប់វគ្គសិក្សាវិជ្ជាជីវៈរបស់ TAFE;
- សិស្ស 11 នាក់ បានចូលរៀនក្នុងវគ្គសិក្សាស្វាគមន៍ភ្ញៀវ Salvation Army Café Horizons; ហើយ
- សិស្ស Year 7 ចំនួន 63 នាក់ ចាប់ពីសាលាបឋមសិក្សាដល់សាលាមធ្យមសិក្សា មានផែនការសិក្សាអប់រំរៀងៗខ្លួន ដែលសរសេរជាលាយលក្ខណ៍អក្សរសំរាប់ពួកគេ។

សាលាមធ្យមសិក្សាទាំងអស់ក្នុងតំបន់ បានចូលរួមនៅក្នុងសិក្ខាសាលារយៈពេលពីរថ្ងៃ ដើម្បីពិនិត្យឡើងវិញនូវបញ្ហាសុខភាពរបស់ជនពេញជំទង់។ ឥឡូវនេះ បុគ្គលិកកំពុងអនុវត្តផែនការការងារ ដើម្បីដោះស្រាយបញ្ហាទាំងពួង ពាក់ព័ន្ធនឹងការសិក្សាអប់រំអំពីបញ្ហាគ្រឿងញៀន ចាប់ពី Year 7 ដល់ Year 10 ។

**Families First និង Primary Connect**

សាលារៀនអាចផ្តល់ទីកន្លែងមានប្រសិទ្ធភាពមួយ សំរាប់ជួយឲ្យមានចំណងទាក់ទងល្អប្រសើររវាងកុមារនិងបណ្តាជនវ័យក្មេង ហើយនិងគ្រួសាររបស់គេនិងសហគមន៍ទាំងពួង។

***Families First program*** (កម្មវិធីគ្រួសារជាដំបូង) កំពុងផ្តល់ជំនួយទៅឲ្យពលរដ្ឋរវាង 70 – 100 គ្រួសាររួចទៅហើយ ដែលមានកូនអាយុតិចជាង 8 ឆ្នាំ នៅឯសាលារៀននានាក្នុងតំបន់កាប្រាម៉ាតា, Canley Vale, Bonnyrigg និង Fairfield ។

នៅក្រោមកម្មវិធីនេះ សាលាក្នុងតំបន់ក្លាយជា"កន្លែងប្រសព្វ"សំរាប់មាតាបិតានិងសហគមន៍ ដោយផ្តល់:

- សកម្មភាពពាក់ព័ន្ធនឹងគ្រួសារនិងកុមារ ដូចជាក្រុមលេងដែលទទួលជំនួយ ដើម្បីជួយបណ្តាគ្រួសារក្នុងការស្ថាបនាចំណងទាក់ទងក្នុងរង្វង់និងខាងក្រៅក្រុមគ្រួសារ;
- ជំនួយរបស់អ្នកណែនាំសំរាប់គ្រួសារ ជាពិសេសនៅក្នុងឆ្នាំមុនចូលសាលារៀន និងនៅក្នុងឆ្នាំដំបូងនៃការចូលសាលារៀន;
- ការផ្តួចផ្តើមទាំងពួងដែលវាក់វិននឹងសុខភាព;
- ថ្នាក់បង្ហាត់ជំនាញការភាសា; ហើយនិង
- ការបញ្ជូនទៅកាន់សេវាកម្មនានាក្នុងតំបន់ និងពត៌មានអំពីសេវាកម្មទាំងឡាយ ការរីកចំរើនរបស់កុមារ និងការចិញ្ចឹមបីបាច់កូន។

នៅត្រឹមពាក់កណ្តាលឆ្នាំ 2002 កម្មវិធីថ្មីមួយហៅថា ***Primary Connect*** (ការតភ្ជាប់បឋម) នឹងមានបន្ថែមទៅលើកម្មវិធីសាលាដូចជាមជ្ឈមណ្ឌលសហគមន៍នេះ។

***Primary Connect*** នឹងផ្តល់ជំនួយសំរាប់កុមារងាយរងគ្រោះ ដែលមានអាយុ 5–12 ឆ្នាំ និងគ្រួសាររបស់គេ ជាពិសេសកុមារដែលប្រហែលជាឈប់រៀនមុនពេលធម្មតា ប្រើគ្រឿងញៀន ប្រព្រឹត្តបទល្មើស និងមានអាកប្បកិរិយាបង្កគ្រោះថ្នាក់ដល់ខ្លួនឯង។ ការរកមើលដឹងនិងដោះស្រាយបញ្ហាទាំងឡាយឲ្យបានទាន់ពេល នឹងបញ្ឈប់កុមារទាំងនោះមិនឲ្យក្លាយទៅជាជនដែលលំបាកនឹងកែប្រែបាន។



### កម្មវិធីសិក្សាអប់រំពហុវប្បធម៌អំពីគ្រឿងញៀន (Multicultural Drug Education Program)

នៅក្នុងកាប្រាម៉ាតា វាជាការសំខាន់ណាស់ដែលធនធានសិក្សាអប់រំអំពីបញ្ហាគ្រឿងញៀនធ្វើទៅតាមសេចក្ដីត្រូវការ របស់សហគមន៍ដែលមានសាវតារមិននិយាយអង់គ្លេស (NESB)។ ក្រសួងរបស់អភិបាលរដ្ឋ កំពុងធ្វើការជាមួយបណ្ដាអង្គការនិងក្រុមសហគមន៍ផ្ដល់ឱវាទក្នុងតំបន់ ដើម្បីបង្កើតកម្មវិធីសិក្សាអប់រំអំពីបញ្ហាគ្រឿងញៀន និងពត៌មានសមស្របសំរាប់គ្រួសារទាំងពួង នៅក្នុងសហគមន៍ វៀតណាម ខ្មែរ លាវ និង ចិន។

### វិធានការសេវាកម្មឆ្លើយតបកាន់តែប្រសើរឡើងសំរាប់បណ្ដាជនវ័យក្មេង

សាលាក្រុង Fairfield និងក្រសួងរបស់អភិបាលរដ្ឋ (Premier's Department) បានរួមដៃគ្នាដើម្បីកោះប្រជុំក្រុមការងារយុវជនមួយ (Youth Action Team) របស់បណ្ដាស្ថាប័នសេវាកម្មរបស់រដ្ឋនិងមិនមែនរបស់រដ្ឋ។ ក្រុមនេះកំពុងស្វែងរកឲ្យដឹងនូវវិធីទាំងឡាយ ដើម្បីកែលំអការផ្ដល់សេវាកម្មទៅឲ្យបណ្ដាជនវ័យក្មេងនៅក្នុងតំបន់។

ឧទាហរណ៍: ក្រុមការងារយុវជនកំពុងបង្កើតវិធានការឆ្លើយតបទៅនឹងបញ្ហានានា ដែលរកមើលដឹងឡើងនៅក្នុងរបាយការណ៍ខែធ្នូ ឆ្នាំ 2001 ថ្ងៃណាក៏ដូចជាថ្ងៃណាដែរ: ភាពគ្មានទីលំនៅរបស់យុវជននៅក្នុងកាប្រាម៉ាតា *(Every day's the same: Youth Homelessness in Cabramatta)* ដែលធ្វើដោយសាលាក្រុង Fairfield និង រដ្ឋាភិបាលនៃរដ្ឋ NSW ។ ក្រុមនេះបានបង្កើតសកម្មភាពបន្ថែមនៅពេលបន្ទាប់មកទៀត ជាមួយនឹងអង្គការពាក់ព័ន្ធទាំងឡាយ ដើម្បីកែលំអការផ្ដល់សេវាកម្មសំរាប់ក្រុមនេះ។

### ការពង្រីកសកម្មភាពបោសសំអាតម្ជុលនិងសឺរាំងនៅក្នុងកាប្រាម៉ាតា

ជនល្មើសទាំងឡាយដែលជាប់ឃុំតាមបញ្ជាឃុំឃាំងតាមរយៈកាល (Periodic Detention Orders) ធ្វើការដើរល្បាតជាទៀងទាត់ ដើម្បីប្រមូលម្ជុលបោះចោល ចេញពីដងផ្លូវនានា។ ការបោសសំអាតនេះ កែលំអដល់ភាពស្រស់បស់នៃតំបន់រស់នៅនិងកន្លែងអាជីវកម្មក្នុងតំបន់ ដោយសំអាតចេញនូវម្ជុលនិងសឺរាំងប្រើហើយ ចេញពីផ្លូវថ្នល់និងតំបន់សាធារណៈទាំងឡាយរបស់កាប្រាម៉ាតា។ ចាប់តាំងពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2001 ក្រុមបោសសំអាតទាំងឡាយ (Clean-up Teams) បានប្រមូលសឺរាំងចំនួន 8 457 ។

បើលោកអ្នកមានឃើញម្ជុលបោះចោលណាមួយ សូមទូរស័ព្ទទៅកាន់**ទូរស័ព្ទពិសេសសំរាប់ការបោសសំអាតម្ជុល (Needle Clean Up Hotline)** ដែលឥតគិតថ្លៃ តាមលេខ **1800 633 353** ។

## Cabramatta Place Project
## (គំរោងការទារទីកន្លែងកាប្រាម៉ាតា)

នៅខែមេសា ឆ្នាំ 1997 ក្រសួងរបស់អភិបាលរដ្ឋ ក្នុងកិច្ចសហការជាមួយសាលាក្រុង Fairfield និងអង្គការឯទៀត បានបង្កើតជា Cabramatta Place Project ដើម្បីដោះស្រាយការប្រើគ្រឿងញៀនខុសច្បាប់ និងផលប៉ះពាល់របស់វា ទៅលើសហគមន៍កាប្រាម៉ាតា។

Cabramatta Place Project កំពុងអនុវត្តវិធីសាស្រ្តប្រឆាំងគ្រឿងញៀននៅតាមថ្នាក់តំបន់។ កិច្ចការក៏កំពុងធ្វើតទៅទៀតផងដែរ លើបញ្ហាផ្សេងៗ ដូចជាការអភិវឌ្ឍន៍ទេសចរណ៍ និងការកែលំអភាពឆើតឆាយនៃតំបន់ក្រុង (សាលាក្រុង Fairfield ដឹកនាំកិច្ចការទាំងពីរនេះ) ហើយនិងការសិក្សាអប់រំនិងហ្វឹកហ្វឺនការងារសំរាប់បណ្ដាជនវ័យក្មេង។

ដើម្បីទទួលពត៌មានបន្ថែម សូមទាក់ទង Senior Project Manager, Cabramatta Place Project តាមទូរស័ព្ទលេខ 9724 7811 ។

## ពត៌មានបន្ថែម

### ត្រូវការជំនួយឬ?

បើលោកអ្នក ឬនរណាមួយដែលលោកអ្នកស្គាល់ ត្រូវការជំនួយ ឬឱវាទដែលលាក់ការណ៍សម្ងាត់អំពីគ្រឿងញៀន សូមទូរស័ព្ទទៅកាន់**សេវាកម្មពត៌មានសុរានិងគ្រឿងញៀន (Alcohol and Drug Information Service / ADIS)** តាមទូរស័ព្ទលេខ 9361 8000 (តំបន់ក្រុងស៊ីដនីតែប៉ុណ្ណោះ) ឬទូរស័ព្ទឥតគិតថ្លៃ តាមលេខ 1800 422 599 (នៅខាងក្រៅក្រុងស៊ីដនី)។

ADIS បើកទ្វារធ្វើការគ្រប់ពេលម៉ោងទាំងអស់ ដើម្បីផ្ដល់ឱវាទ ពត៌មាន និងការបញ្ជូនដោយលាក់ការណ៍សម្ងាត់ ទៅកាន់អង្គការទាំងពួងក្នុងតំបន់។

ក្នុងភាពជាមាតាឬបិតា ការដោះស្រាយបញ្ហាគ្រឿងញៀន អាចជាការលំបាកខ្លាំងណាស់។ ដើម្បីទទួលឱវាទអំពីរបៀបនិយាយទៅកាន់បណ្ដាជនវ័យក្មេងអំពីការប្រើគ្រឿងញៀន ឬបញ្ហាឥរិយាបថ សូមទាក់ទង**ទូរស័ព្ទផ្ដល់ឱវាទសំរាប់មាតាបិតា (Parent Line)** ដែលឥតគិតថ្លៃ តាមលេខ **13 20 55** ។

### ការរាយការណ៍អំពីឧក្រិដ្ឋកម្មគ្រឿងញៀន

ពត៌មានណាមួយដែលលោកអ្នកមាន អំពីឧក្រិដ្ឋកម្មគ្រឿងញៀន សូម្បីតែលោកអ្នកយល់ថាមិនសំខាន់ក្ដី អាចជួយប៉ូលិសឲ្យធ្វើការចាប់ខ្លួនជនល្មើស។ ដើម្បីរាយការណ៍អំពីឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងគ្រឿងញៀន សូមទូរស័ព្ទទៅកាន់**អ្នកបញ្ឈប់ឧក្រិដ្ឋកម្ម (Crime Stoppers)** តាមទូរស័ព្ទឥតគិតថ្លៃ លេខ **1800 333 000** ។

### ចង់ដឹងពត៌មានបន្ថែមឬទេ?

បើលោកអ្នកចង់ដឹងពត៌មានបន្ថែមអំពីវិធានការឆ្លើយតបរបស់រដ្ឋាភិបាល NSW ទៅនឹងបញ្ហាគ្រឿងញៀន សូមបើកមើលគេហទំព័រអ៊ីនធើរណិត **www.druginfo.nsw.gov.au**

នៅឯ **www.druginfo.nsw.gov.au** លោកអ្នកនឹងទទួលពត៌មានបន្ថែមអំពីគ្រឿងញៀន គំរោងការងារ និងវិធានការដែលកំពុងធ្វើឡើង ដើម្បីដោះស្រាយបញ្ហាគ្រឿងញៀន។ គេហទំព័រអ៊ីនធើរណិតនេះ ក៏មានឯកសារស្ដីអំពីផែនការការងារនៃសន្និសីទគ្រឿងញៀន *(Drug Summit Plan of Action)* របស់រដ្ឋាភិបាល NSW ពត៌មានឯទៀត និងការតភ្ជាប់ទៅកាន់គេហទំព័រអ៊ីនធើរណិតដែលពាក់ព័ន្ធផ្សេងទៀតផងដែរ។